ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2016, 11:37
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៩:២៦នាទី**

**សវនាការលើកទី៣៩៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ
*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:២៦:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះកំណត់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-827 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តលើក្រុមគោលដៅមនុស្សជាក់លាក់ចំពោះជនជាតិចាម។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោក នួន ជា អវត្តមានដោយមូលហេតុសុខភាព។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-827 ប៉ុន្តែរហូតមកដល់ពេលនេះ សាក្សីរូបនេះមិនមានវត្តមាននៅក្នុងតុលាការនោះទេ។ ហើយនៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:២៧:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ តាមរបាយការណ៍របស់វេជ្ជបណ្ឌិតប្រចាំការនៅ អ.វ.ត.ក ដែលបានពិនិត្យសុខភាពរបស់ លោក នួន ជា នៅថ្ងៃនេះ បានបង្ហាញថា លោក នួន ជា មានអាការៈវិលមុខខ្លាំង ឈឺក្បាល ធេងធោង ឈឺចង្កេះ ដោយស្ថានភាពសុខភាពនៅថ្ងៃនេះ មិនល្អទេ ដោយមានបញ្ហាសម្ពាធឈាមឡើងខ្ពស់ ឈឺក្បាលនិងវិលមុខខ្លាំង និងបានផ្តល់អនុសាសន៍ថាគាត់ នួន ជា មិនអាចចូលរួមនៅក្នុងសវនាការនេះបានទេ ព្រោះគាត់មិនអាចផ្ចង់អារម្មណ៍បាន។

ហើយម្យ៉ាងទៀត គឺអង្គជំនុំជម្រះបានឃើញដីកាបង្គាប់ឲ្យនាំខ្លួនសាក្សី 2-TCW-827 ដែលមានលេខឯកសារ E202/208/2 ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦ ប៉ុន្តែរហូតមកដល់ពេលនេះ សាក្សី

2-TCW-827 មិនៗមានវត្តមាននៅ អ.វ.ត.ក ទេ ហើយអង្គជំនុំជម្រះសង្ឃឹមថា នឹងទទួលបាននូវរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានតួនាទីក្នុងការអនុវត្តដីកានេះ ឆាប់ៗចំពោះករណីនេះ។

ហើយហេតុដូច្នេះអង្គជំនុំជម្រះមិនអាចធ្វើសវនាការនៅថ្ងៃនេះបានទេ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះស្នើសុំឲ្យភាគីតាមដាននូវសារអេឡិចត្រូនិចរបស់ខ្លួនឲ្យបានជាប់ ពាក់ព័ន្ធនឹងលទ្ធភាពនៃកិច្ចដំណើរការសវនាការដែលអាចនឹងធ្វើនៅថ្ងៃស្អែក។

ហេតុដូច្នេះសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើទៅតាមលទ្ធភាពជាក់ស្តែងដែលនៃថ្ងៃស្អែក តើប្រព្រឹត្តទៅបានឬក៏មិនបានយ៉ាងណា ដែលអង្គជំនុំជម្រះនឹងជូនដំណឹងទៅតាមសារអេឡិចត្រូនិច តាមរយៈរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ អ.វ.ត.ក.។

ហើយបង្គាប់ឲ្យអនុក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក. វិញចុះ ហើយឯដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូប ចូលរួមសវនាការជាបន្តទៅមុខនោះ រង់ចាំដីកាបង្គាប់ជាថ្មីពីអង្គជំនុំជម្រះ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ០៩:៣១ នាទី)*